# **គ្រាកាន់កាប់ត្រួតត្រា. . .គឺជាទំនុកចិត្តដ៏ពិសិដ្ឋមួយ**

អែលឌើរ ឃ្វីនថិន អិល ឃុក
ក្រុមនៃពួកសាវក 12 នាក់

*យើងបំរើបងប្អូនយើង ពីព្រោះនោះគឺជាអ្វីដែលយើងជឿថាព្រះចង់ឱ្យយើងធ្វើ ។*

យើងរស់នៅក្នុងគ្រាដ៏លំបាក ដែលមនុស្សភាគច្រើនជឿថា យើងនឹងពុំមានទំនួលខុសត្រូវចំពោះព្រះ ហើយថាយើងពុំមានទំនួលខុសត្រូវផ្ទាល់ខ្លួន ឬការកាន់កាប់កិច្ចការផ្ទាល់សំរាប់ខ្លួនយើង ឬអ្នកដទៃនោះទេ ។ មានមនុស្សជាច្រើនក្នុងពិភពលោកបានផ្តោតទៅលើការ បំពេញចិត្តខ្លួនឯង ដោយគិតពីខ្លួនឯងជាមុនសិន ហើយចូលចិត្តនឹងភាពរីករាយ ជាជាងស្រឡាញ់សេចក្តី-សុចរិត ។ ពួកគេពុំបាន ជឿថា ពួកគេគឺជាអ្នកថែរក្សាបងប្អូនរបស់ខ្លួននោះទេ ។ ទោះជាយ៉ាង ណាក៏ដោយ នៅក្នុងសាសនាចក្រ យើងជឿថា កិច្ចការកាន់កាប់ទាំងនេះគឺជាការទុកចិត្តដ៏ពិសិដ្ឋមួយ ។

ថ្មីៗនេះ មានក្រុមពួកអ្នកដឹកនាំ និងអ្នកប្រាជ្ញសាសន៍យូដាដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ បានមកទស្សនកិច្ចអគារសាសនាចក្រ នៅក្នុង ទីក្រុង សលត៍ លេក រួមមាន វិសាលដ្ឋានសុខុមាលភាព មជ្ឈមណ្ឌលមនុស្សធម៌ មជ្ឈមណ្ឌល ពង្សប្រវត្តិ និងការបើកសម្ពោធ ព្រះវិហារបរិសុទ្ធភ្នំអូហ្គី ។ នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ចរបស់ពួកគេ នោះមានអ្នកប្រាជ្ញដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញមួយរូបនៅក្នុងប្រទេសអាមេរិក បានសម្តែងចេញពីអារម្មណ៍របស់ខ្លួនចំពោះអ្វីដែលគាត់បានមើលឃើញ និងបានទទួលអារម្មណ៍ ។ 1

គាត់បានដកស្រង់នូវទស្សនៈមួយចំនួនមកពីពួកទស្សនវិទូសាសន៍យូដា ដែលបានចាក់ឫសនៅក្នុងក្រិត្យវិន័យពីបុរាណរបស់សាសន៍យូដា 2 ហើយបានចង្អុលបង្ហាញថា មានហេតុផលផ្សេងគ្នាពីរ យ៉ាងដែលធ្វើឱ្យមនុស្សចូលប្រឡូកនៅក្នុងទង្វើរដែលមានចិត្តមេត្តាករុណា និងចិត្តសប្បុរស ។ មានមនុស្សមួយចំនួន បានទៅមើលអ្នកឈឺ ជួយដល់អ្នកក្រ ហើយបានបំរើដល់មនុស្សដទៃទៀត ពីព្រោះពួកគេជឿថា វាគឺជារឿងដ៏ត្រឹមត្រូវដើម្បីធ្វើ ហើយមនុស្សផ្សេងទៀតនឹងតបស្នងមកវិញនូវទង្វើរដូចគ្នានេះ នៅពេលពួកគេមានការខ្វះខាតនោះ ។ គាត់បានពន្យល់ថា ការណ៍នេះគឺជារឿងដ៏ល្អមួយ នៅពេលយើងបំរើដល់មនុស្សដទៃ ដោយដឹងថា នោះគឺជាអ្វីដែលព្រះសព្វព្រះទ័យឱ្យយើងធ្វើ នោះវានឹងបង្កើតឡើងជាសហគមន៍ដែលចេះជួយគ្នាទៅវិញទៅមក ហើយវានឹងត្រូវបានគេគិតថាជាហេតុផលដ៏ថ្លៃថ្នូរ និងជាការលើកទឹកចិត្តដ៏ខ្ពង់ខ្ពស់មួយផងដែរ ។

គាត់បានលើកឡើងទៀតថា ជាលទ្ធផលនៃទស្សនកិច្ចរបស់គាត់ នោះបានជឿថា ពួកបរិសុទ្ធថ្ងៃចុងក្រោយបានអនុវត្តនូវកិច្ចការសុខុមាលភាព មនុស្សធម៌ និងកិច្ចការនៃសេចក្តីសង្គ្រោះនៅក្នុងព្រះវិហារបរិសុទ្ធរបស់យើង ដើម្បីធ្វើនូវអ្វីដែលព្រះសព្វព្រះទ័យឱ្យយើងធ្វើ ។

អារម្មណ៍នៃការទទួលខុសត្រូវ ដែលមាននៅក្នុងព្រះបញ្ញត្តិដ៏ធំទីមួយឱ្យស្រឡាញ់ដល់ព្រះ នោះបានលើកឡើង ដោយមនុស្សមួយចំនួនថាជា "ការគោរពដោយគ្មានការបង្ខិតបង្ខំ"។3 យើងបានព្យាយាមធ្វើអ្វីដែលត្រឹមត្រូវ ពីព្រោះយើងស្រឡាញ់ និងចង់ធ្វើឱ្យព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌សព្វព្រះទ័យ ប៉ុន្តែពុំមែនដោយសារនរណាម្នាក់បង្ខំយើងឱ្យគោរពតាមនោះទេ។ ចម្បាំងនៅស្ថានសួគ៌បានកើតមានឡើង បន្ទាប់ពីសាតាំងបានលើកឡើងពីផែនការមួយដែលនឹងបង្ខំមនុស្សគ្រប់គ្នាឱ្យគោរពតាមគំនិតរបស់វានោះ។ ផែនការរបស់វាត្រូវបានបដិសេធ។ ជាលទ្ធផល យើងបានទទួលនូវសិទ្ធិជ្រើសរើស ខាងសីលធម៌របស់យើង និងសិទ្ធិសេរីភាពដើម្បីជ្រើសរើសយកផ្លូវដែលយើងត្រូវដើរនៅក្នុងជីវិតនេះ។ ប៉ុន្តែយើងក៏ត្រូវទទួលខុសត្រូវចំពោះសិទ្ធិជ្រើសរើសនោះដែរ។ ព្រះអម្ចាស់បានមានបន្ទូលថា យើងនឹង "ទទួលការខុសត្រូវចំពោះ អំពើបាបទាំងឡាយ [របស់យើង] នៅថ្ងៃជំនុំជំរះ"។4 គោលការណ៍នៃទំនួលខុសត្រូវ និងការកាន់កាប់ត្រួតត្រា គឺមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងគោលលទ្ធិរបស់យើង។5

ចំពោះការកាន់កាប់ត្រួតត្រាក្នុងសាសនាចក្រ គឺ *មិន* បានកំណត់ចំពោះទំនុកចិត្ត និងទំនួលខុសត្រូវ*ខាងសាច់ឈាម* នោះទេ។ ប្រធាន ស្ពែនស៊ើរ ដបុលយូ឵ ឃីមបឹល បានបង្រៀនថា "យើង គឺជាអ្នកកាន់កាប់ត្រួតត្រាចំពោះរូបកាយ គំនិត ក្រុមគ្រួសារ និងទ្រព្យសម្បត្តិរបស់យើង។ អ្នកកាន់កាប់ដ៏ស្មោះត្រង់ម្នាក់ គឺជាបុគ្គលម្នាក់ដែលអនុវត្តការត្រួតត្រាដោយសុចរិត ចេះខ្វល់ខ្វាយចំពោះគ្រួសាររបស់ខ្លួន និងចេះមើលថែដល់អ្នកក្រ និងអ្នកខ្វះខាត"។6

ដោយសារតែការកាន់កាប់ត្រួតត្រាមានច្រើនផ្នែកពេក ដូច្នេះនៅពេលនេះ ខ្ញុំសូមលើកយកមកនិយាយតែពីរចំណុចប៉ុណ្ណោះ។ ចំណុចទីមួយ គឺជាការកាន់កាប់ត្រួតត្រាលើខ្លួនយើង និងក្រុមគ្រួសាររបស់យើង។ ចំណុចទីពីរ គឺជាការកាន់កាប់ត្រួតត្រាលើអ្នកក្រីក្រ និងអ្នកខ្វះខាត។

ជាញឹកញាប់ ព្រះអម្ចាស់បានប្រើរឿងប្រៀបធៀបដែលទាក់ទងនឹងដែនដី នៅក្នុងការបង្រៀនពីទំនួលខុសត្រូវ និងការកាន់កាប់ត្រួតត្រា។ កាលពីនៅក្មេង ខ្ញុំតែងតែទៅលេងនឹងលោកតាលោកយាយរបស់ខ្ញុំនៅឯកសិដ្ឋានរបស់គាត់នាវដូវក្តៅ។ នៅទីនោះគឺគ្មានភ្លើងអគ្គីសនី ឬទឹក ឬបំពង់ទឹកក្នុងអគារឡើយ។ ប៉ុន្តែ មានក្បាលទឹកមួយ កន្លែងនៅក្បែរផ្ទះកសិដ្ឋានដ៏តូចរបស់ពួកគេ។ ក្បាលទឹកនោះបានបង្កើតជាស្រះមួយដែលមានទឹកថ្លាឆ្វង់ ជាទីកន្លែងដែលខ្ញុំបានជួយលោកយាយរបស់ខ្ញុំយួរទឹកពីរទៅបីដងក្នុងមួយថ្ងៃ ដើម្បីទុកសំរាប់បរិភោគ សំរាប់ចំអិនអាហារ សំរាប់ងូត និងសំរាប់បោកសំលៀកបំពាក់។ លោកតាលោកយាយរបស់ខ្ញុំចូលចិត្តរស់នៅក្នុងជីវិតបែបនេះ ហើយមានការប្រុង ប្រយ័ត្នជាពិសេសដើម្បីការពារក្បាលទឹកនោះ។

ច្រើនឆ្នាំក្រោយមក លោកតារបស់ខ្ញុំបានឈានចូលវ័យកៅសិបឆ្នាំ ហើយគាត់មិនរស់នៅទីនោះទៀតឡើយ ហើយក៏គ្មានលទ្ធភាពដើម្បីថែរក្សា ឬគ្រប់គ្រងវាបានដែរ។ ខ្ញុំបានបើករថយន្តដឹកគាត់ទៅមើលកសិដ្ឋានជាទីស្រឡាញ់របស់គាត់។ ការទន្ទឹងរបស់គាត់ចង់ឃើញកសិដ្ឋាននោះបានប្រែក្លាយទៅជារឿងខកចិត្តវិញ គឺនៅពេលគាត់បានដឹងថា របងការពារក្បាលទឹកនោះបានដួលទ្រុឌទ្រោម ហើយមានសត្វគោជាច្រើនបានបំផ្លាញក្បាលទឹកនោះ ហើយបានធ្វើឱ្យវាមានភាពល្អក់យ៉ាងខ្លាំង។ ចំពោះគាត់ វាគឺជាការបំពានទៅលើទំនុកចិត្តដែលគាត់ខិតខំថែរក្សាពេញមួយជីវិតរបស់គាត់។ គាត់ទទួលអារម្មណ៍ថា គាត់មិនបានការពារក្បាលទឹកដែលធ្លាប់បានជួយដល់ជីវិតរបស់គាត់យ៉ាងច្រើននោះឡើយ។

ការមិនបានការពារ រហូតបានធ្វើឱ្យក្បាលទឹកដ៏ថ្លានោះទទួលនូវភាពល្អក់កករ គឺប្រៀបបាននឹងពេលដែលយើងរស់នៅ ដោយគ្មានការការពារចំពោះគុណធម៌ និងបរិសុទ្ធភាពដូច្នោះដែរ។ 7 សារៈសំខាន់ដ៏នៅអស់កល្បជានិច្ចចំពោះសីលធម៌ផ្ទាល់ខ្លួន គឺពុំមែនគ្មានគុណតម្លៃនោះទេ។ ព្រះវរបិតាជាទីស្រឡាញ់ដែលគង់នៅស្ថានសួគ៌បានប្រទានមធ្យោបាយឱ្យយើង ដើម្បីនាំយកកូនចៅវិញ្ញាណរបស់ទ្រង់មកកាន់ពិភពលោកនេះ ដើម្បីបំពេញនូវកិរិតនៃការបង្កបង្កើតរបស់ពួកគេ។ ទ្រង់បានណែនាំយើងថា គ្រឹះនៃជីវិត គឺត្រូវរក្សាឱ្យបរិសុទ្ធ ដូចជាក្បាលទឹកដ៏ស្រស់ប្រណិតនៅឯកសិដ្ឋានោះដែរ វាតំរូវឱ្យមានការការពារ ដើម្បីជួយផ្គត់ផ្គង់ដល់ជីវិត។ នេះគឺជាហេតុផលមួយដែលគុណធម៌ និងបរិសុទ្ធភាព គឺជាកត្តាដ៏សំខាន់នៅក្នុងផែនការរបស់ព្រះវរបិតាយើង ដែលគង់នៅស្ថានសួគ៌។

ដោយសារតែប្រតិកម្មរបស់លោកតាខ្ញុំចំពោះភាពល្អក់នៅក្នុងក្បាលទឹកនោះ ទើបធ្វើឱ្យមានការកែលំអ និងការការពារ ដើម្បីធ្វើឱ្យក្បាលទឹកនោះមានសភាពស្រស់ប្រណិត និងមានទឹកថ្លាឆ្វង់ដូចដើមវិញ។

ក្នុងនាមជាអ្នកបំរើនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ការបង្រៀនពីបទដ្ឋានសីលធម៌របស់ទ្រង់ ដែលមានសំរាប់កូនចៅរបស់ទ្រង់ទាំងអស់ដូចគ្នា គឺជាទំនួលខុសត្រូវដ៏ពិសិដ្ឋរបស់យើង។ នៅពេលគំនិត និងទង្វើររបស់យើងមាន ភាពកខ្វក់ នោះយើងបានបំពានចំពោះបទដ្ឋានរបស់ទ្រង់ហើយ។ ព្រះអម្ចាស់បានមានបន្ទូលថា "យើង...ពុំអាចទតមើលអំពើបាប សូម្បីតែបន្តិចបន្តួចបានឡើយ"។8 មានមនុស្សមួយចំនួនបានព្យាយាមកាត់បន្ថយនូវចរិយាល្អរបស់ខ្លួន។

នៅក្នុងកំណាព្យមួយរបស់លោក យ៉ូហាន ហូមីស ដែលមានចំណងជើងថា "អ្នកធ្វើកប៉ាល់វ័យចំណាស់គរមកពីប្រទេសអង់គ្លេស ថ្មីបង្រៀនដល់យុវជនម្នាក់ទៀតពីការគណនា។ ក្នុងការពិពណ៌នាអំពីមេរៀនមួយដែលយុវជននោះបានរៀន យុវជនបានពន្យល់ថា "ខ្ញុំពុំដឹងថាអ្នកសង់កប៉ាល់យ៉ាងណាទេ កប៉ាល់ត្រូវតែជិះទៅមុខបាន អ្នកពុំអាចពន្យល់ដល់សមុទ្រនោះទេ"។9

មានយោបល់ថាអ្វីដែលយើងកើតឡើងនៅក្នុងទីក្រុងមួយ គឺនៅជាប់នឹងទីក្រុងនោះឯង។ ខ្ញុំចូលចិត្តស្លាកសញ្ញាដែលបានដាក់បង្ហាញនៅក្នុងក្រុង សីវឺ រដ្ឋ យ៉ូថាហ៍ ដែលបានសរសេរថា : "អ្វីដែលកើតមាននៅក្នុងក្រុង ស៊ីវឺ ...អ្នកអាចចែកចាយជាមួយនឹងមិត្តភក្តិរបស់អ្នកបាន!!!" នៅពេលយើងដឹងថា យើងមានទំនួលខុសត្រូវចំពោះព្រះ នោះយើងនឹងមើលឃើញពីភាពល្ងីល្ងើរនៃការធ្វើឱ្យមើលឃើញថាសមហេតុផលទាំងឡាយ។ ពួកអ្នកដែលចង់ធ្វើឱ្យឃើញថាសមហេតុផល បានរំលឹកយើងពីកុមារតូចៗដែលបានបិទភ្នែកខ្លួនឯង ដោយជឿថា បើពួកគេមើលយើងមិនឃើញ នោះយើងក៏មិនអាចមើលគេឃើញដែរ។ 11 ខ្ញុំសូមណែនាំថា បើយើងគិតចង់រៀបរាប់ពីទង្វើររបស់យើងចំពោះព្រះអង្គសង្គ្រោះ នោះយើងនឹងស្គាល់ពីសេចក្តីពិតអំពីការចង់ធ្វើឱ្យឃើញថាសមហេតុផលរបស់យើង។

យើងបានដឹងជាមុនហើយថា មានពួកអ្នកដែលមិនប្រកាន់ខ្ជាប់នូវបទដ្ឋានសីលធម៌ដ៏ពិសិដ្ឋនេះ។ សូមយល់ថា តាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ នោះមនុស្សគ្រប់គ្នាអាចប្រែចិត្ត ហើយត្រឡប់មកដូចជាក្បាលទឹកនោះវិញ ដោយស្ថិតនៅក្នុងសភាពស្អាតស្អំ និងបរិសុទ្ធ។ ការប្រែចិត្តមានការលំបាក។ វាតំរូវឱ្យមានចិត្តសង្រេង និងវិញ្ញាណទន់ទាប។ 10 ប៉ុន្តែ នៅពេលជំហាន

ទាំងឡាយនៃការប្រែចិត្តត្រូវបានធ្វើតាមដោយសុចរិត នោះពាក្យសម្ដីដែលព្យាការី អាលម៉ាបាននិយាយទៅកាន់កូនប្រុសរបស់គាត់ កូរីអាតុន ដែលបានពាក់ព័ន្ធនឹងអំពើរំលងខាងសីលធម៌ គឺអាចយកមកអនុវត្តបាន ៖ "ហើយឥឡូវនេះ កូនប្រុសរបស់ឪពុកអើយ ឪពុកពុំមានបំណងចង់ឱ្យរឿងទាំងនេះ ធ្វើឱ្យកូនកង្វល់ចិត្ត តទៅទៀតទេ ហើយទុកឱ្យតែអំពើបាបរបស់កូនបារម្ភដល់កូនតែប៉ុណ្ណោះបានហើយ គឺការបារម្ភនេះហើយដែលអាច ញ៉ាំងឱ្យកូនប្រែចិត្ត"។ ព្រះអង្គសង្គ្រោះ បានមានបន្ទូលថា "មើលចុះ អ្នកណាដែលប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួន អ្នកនោះ ឈ្មោះថា បានអត់ទោសឱ្យហើយ ហើយយើងជាព្រះអម្ចាស់មិនចាំពីអំពើបាបទាំងនោះទៀតទេ"។12

ដោយគោរពចំពោះកិច្ចការរបស់យើងសំរាប់ក្រុមគ្រួសាររបស់យើង មនុស្សមួយចំនួនបានបង្រៀនថា នៅពេលយើងរាយការណ៍ទៅកាន់ព្រះអង្គសង្គ្រោះ ហើយទ្រង់សុំឱ្យយើង រៀបរាប់ពីទំនួលខុសត្រូវនៅលើផែនដីរបស់យើង នោះមានសំណួរពីរដ៏សំខាន់ និងសួរទាក់ទងនឹងទំនាក់ទំនងគ្រួសាររបស់យើង។ ដំបូងគឺជាទំនាក់ទំនងរវាងស្វាមី ឬភរិយារបស់យើង និងអំពីកូនចៅម្នាក់ៗរបស់យើង។13

នោះវាងាយស្រួលធ្វើឱ្យយើងច្របូកច្របល់ ចំពោះអាទិភាពរបស់យើងណាស់។ យើងមានកាតព្វកិច្ចមួយដើម្បីការពារដល់សុវត្ថិភាពខាងសាច់ឈាម និងសុខុមាលភាពរបស់កូនចៅយើង។ ប៉ុន្តែ មានឪពុកម្ដាយមួយចំនួនបានដាក់អាទិភាពយ៉ាងច្រើនទៅលើទ្រព្យសម្បត្តិខាងលោកិយ និងផ្នែកសម្ភារ។

មានឪពុកម្ដាយមួយចំនួនទៀតខ្វះភាពឧស្សាហ៍ព្យាយាមដើម្បីបង្រៀនដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដល់កូនចៅរបស់ខ្លួន។ 14 សូមចងចាំថា ការមានការអនុវត្តន៍សាសនានៅក្នុងគេហដ្ឋាន គឺមានសារៈសំខាន់ដូចគ្នានឹងការផ្ដល់ម្ហូបអាហារ សំលៀកបំពាក់ និងទីជំរកផងដែរ។ ឪពុកម្ដាយទាំងឡាយក៏អាចជួយកូនៗទាំងឡាយឱ្យរក ឃើញនូវទេពកោសល្យរបស់ពួកគេ ហើយធ្វើការអភិវឌ្ឍន៍វាផងដែរ។ យើងមានទំនួលខុសត្រូវចំពោះទេពកោសល្យដែលយើងបានទទួល។ កុមារទាំងឡាយដែលមិនបានបង្រៀនថា ពួកគេត្រូវមានទំនួលខុសត្រូវចំពោះពេលវេលា និងទេពកោសល្យរបស់ខ្លួននឹងទទួលរងនូវភាពល្ងង់ខ្លៅ និងមិនសុចរិតដែលកំពុងតែរីករាលដាលយ៉ាងខ្លាំងនៅក្នុងពិភពលោកនេះ។15 ការប្រកាសអំពីក្រុម គ្រួសារបានព្រមានថា បុគ្គលទាំងឡាយណាដែល "មិនបានបំពេញកិច្ចការនៃគ្រួសារ គង់តែថ្ងៃណាមួយនឹងទទួលខុសត្រូវ នៅចំពោះព្រះ"។16

ការកាន់កាប់ត្រួតត្រាទីពីរ គឺជាការមើលថែដល់មនុស្សទាល់ក្រ និងទុរគត ដែលជាក់ស្ដែងអនុវត្តចំពោះយើងទាំងអស់គ្នា នៅគ្រាណាមួយមិនខាន។ ពាក្យទូន្មានរបស់ព្រះអម្ចាស់ដែលលើកឡើងថា យើងគឺជាអ្នកកាន់កាប់ចំពោះអ្នកទាំងឡាយ ដែលខ្វះខាតដោយបង្កប់នូវបន្ទូលដ៏មឺុងម៉ាត់មួយចំនួនក្នុងព្រះគម្ពីរទាំងអស់។ "...បើសិនជាមានមនុស្សណាមួយយកពី របស់បរិបូរដែលយើងបានបង្កើតមក ហើយពុំចែកចំណែករបស់ខ្លួន... ដល់មនុស្សទាល់ក្រ និងមនុស្សកំសត់ទុគ៌តទេ អ្នកនោះនឹងសម្លឹងភ្នែកឡើង នៅក្នុងស្ថាននរកជាមួយមនុស្ស ទុច្ចរិតនៅក្នុងការរងទុក្ខវេទនា"។ 17 យើងមានទំនួលខុសត្រូវក្នុង នាមជាអ្នកកាន់កាប់លើពរជ័យលើផែនដីនេះ ដែលព្រះអម្ចាស់បានប្រទាន ឱ្យ។

ពួកអ្នកដឹកនាំសាសន៍យូដា ដែលខ្ញុំបានលើកឡើងកាលពីដើមនោះ បានកោតសរសើរចំពោះគោលការណ៍នៃការតមអាហារ រួចហើយធ្វើការបង់ដង្វាយតមអាហារដ៏សប្បុរសនោះ។ ពួកគេបានគិតថា វាគឺជារឿងអស្ចារ្យណាស់ដែល សមាជិកសាសនាចក្រ នៅជុំវិញពិភពលោក បានធ្វើការតមអាហារជារៀងរាល់ខែ រួចហើយបានបង់ដង្វាយតាមសទ្ធារបស់ខ្លួន ដើម្បីជាប្រយោជន៍ដល់ពួកអ្នកទុគត។

នៅពេលពួកអ្នកប្រាជ្ញទាំងនោះបានទៅទស្សនកិច្ចនៅឯវិសាលដ្ឋានសុខុមាល នោះពួកគេបានយល់យ៉ាងច្បាស់ថា ទោះជាស្ថិតនៅក្នុងគ្រានៃវិបត្តិសេដ្ឋកិច្ចក្តី ក៏សមាជិករបស់យើង ដែលមានចិត្តខ្វល់ចំពោះឧបសគ្គទាំងឡាយ ដែលមានមនុស្សជាច្រើនកំពុងជួបប្រទះនោះ បានបន្តធ្វើការបរិច្ចាគដោយក្តីសប្បុរសចំពោះការជួយដល់មនុស្សទាល់ក្រ និងទុរគតផងដែរ។

ខ្ញុំនៅចាំបាន កាលពីខ្ញុំត្រូវបានហៅឱ្យធ្វើជាប៊ីស្សព នោះប៊ីស្សព វ៉ាស់សេរុល ចនសិន ដែលជាអតីតប៊ីស្សព បានដាស់តឿនខ្ញុំថា ខ្ញុំត្រូវមានការប្រុងប្រយ័ត្នចំពោះអ្វីដែលខ្ញុំស្នើសុំឱ្យសមាជិកធ្វើ។ គាត់បានមានប្រសាសន៍ថា "សមាជិកមួយចំនួននឹងឆ្លើយតបចំពោះការទូន្មានទាំងឡាយ ទោះជាត្រូវលះបង់ប៉ុណ្ណាក៏ដោយ"។ គាត់បានប្រាប់ខ្ញុំពីស្ត្រីមេម៉ាយម្នាក់មានវ័យប៉ែតសិបឆ្នាំ ជាអ្នកដែលបានមើលថែស្វាមី និងកូនប្រុសដែល មានជម្ងឺរ៉ាំរ៉ៃយូរឆ្នាំរហូតដល់ពួកគេបានទទួលមរណភាព។ ប៊ីស្សព ចនសិន បានមានប្រសាសន៍ថា ថ្វីបើមាន ធនធានតែបន្តិចបន្តួចក្តី ក៏គាត់បានព្យាយាមធ្វើតាមការស្នើសុំដែរ។

ខ្ញុំបានរកឃើញថា នេះគឺជាការពិតមែន។ គ្រប់ពេលដែលខ្ញុំលើកឡើងសេចក្តីត្រូវការសំរាប់ការបរិច្ចាគ ឬការបំរើដើម្បីប្រទានពរដល់មនុស្សដទៃ នោះ សារ៉ា តែងតែជាមនុស្សទីមួយដែលធ្វើតាមការស្នើសុំនោះ។

នាថ្ងៃសៅរ៍មួយ មានបងស្រីម្នាក់បានទូរស័ព្ទប្រាប់ខ្ញុំថា "ប៊ីស្សព សូមអញ្ជើញមកឱ្យលឿនឡើង ជួយដល់ សារ៉ា ផង!" បងស្រីរូបនោះបានប្រាប់ថា "សារ៉ា ដែលមានវ័យ 80 ឆ្នាំ កំពុងនៅលើកាំជណ្តើរជាន់ខ្ពស់បង្អស់ ដើម្បីសំអាតទបង្អួចទឹកភ្លៀងរបស់អ្នកជិតខាងរូបនេះ។ បងស្រីរូបនេះ ភ័យខ្លាចថា សារ៉ា នឹងរអិលធ្លាក់មក ហើយចង់ឱ្យប៊ីស្សពជួយធ្វើអន្តរាគមន៍។

ខ្ញុំមិនបានណែនាំថា មនុស្សគ្រប់គ្នាអាច ឬគួរធ្វើឱ្យដូចជា សារ៉ា នោះទេ។ មនុស្សមួយចំនួនមានអារម្មណ៍ថា ខុសឆ្គង ពីព្រោះពួកគេមិនអាចបំពេញរាល់សេចក្តីត្រូវការភ្លាម១បាន។ ខ្ញុំចូលចិត្តពាក្យដកស្រង់របស់ អានី ម៉ូរ៉ូ លីនប៊ឺហ្គ ដែលអែលឌើរ នែល អេ ម៉ាក់ស្វែល បានយកមកប្រើជាញឹកញាប់ថា "នៅក្នុងជីវិតរបស់ខ្ញុំ ខ្ញុំមិនអាចជួយមនុស្សគ្រប់គ្នាដែលខ្ញុំប្រាថ្នាចង់ជួយនោះឡើយ"។ ស្តេច បេនយ៉ាមីន បានបង្រៀនថា "ចូរឱ្យឃើញថា គ្រប់ការណ៍ទាំងនេះត្រូវបានប្រព្រឹត្តឡើងក្នុងប្រាជ្ញា និងរបៀបរៀបរយ ត្បិតមិនត្រូវ ឱ្យអ្នកណារត់លឿនជាងកម្លាំង ដែលគេមាននោះឡើយ"។ 18 ប៉ុន្តែគាត់បានបន្ថែមទៀតថា យើងគួរតែមានភាពឧស្សាហ៍ព្យាយាម ផងដែរ។ 19

ខ្ញុំមានចិត្តរីករាយ នៅពេលខ្ញុំសង្កេតឃើញពួកបរិសុទ្ធនៅក្នុងសាសនាចក្រទាំងមូលកំពុងធ្វើនូវអ្វីដែលពួកគេអាចធ្វើបាន ដើម្បីផ្តល់ការបំរើដូចជាព្រះគ្រីស្ទ នៅគ្រប់ទីកន្លែងដែលមានសេចក្តីត្រូវការ។ ដោយសារតែការបរិច្ចាគរបស់សមាជិក នោះសាសនាចក្រ

អាចឆ្លើយតបដោយស្ងៀមស្ងាត់ចំពោះសេចក្ដីត្រូវការនៅជុំវិញពិភពលោក ។ 20 សាសនាចក្រកំពុងតែឆ្លើយតបជាស្រេចចំពោះគ្រោះថ្នាក់ធម្មជាតិនៅក្នុងប្រទេសហ្វីលីពីន កោះបាស៊ីហ្វិក និងប្រទេស ឥណ្ឌូណេស៊ី ។

កាលពីឆ្នាំមុន សមាជិករបស់យើងបានឆ្លើយតបទៅនឹងគ្រោះព្យុះ ហ៊ឺរីខេន ហ្គាស្តាយ ។ សាសនាចក្របានធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការមនុស្សធម៌ ដែលដឹកនាំដោយ ស្ដេច ម៉ាទីន លូធឺ ទីបី ។ ក្រោយមក ស្ដេចបានមកទស្សនកិច្ចនៅទីក្រុង ទីក្រុងសលត៍លេក ហើយបានមានប្រសាសន៍ថា ៖ "ដំបូងឡើយ ខ្ញុំមកទីនេះដើម្បីសម្ដែង នូវអំណរគុណរបស់ខ្ញុំចំពោះសាសនាចក្រនេះ សំរាប់ជំនួយផ្នែកមនុស្សធម៌ ប៉ុន្តែរំពេចនោះ ខ្ញុំបានរៀនសូត្រថា ចរិកលក្ខណៈរបស់អ្នកគឺមានភាពជ្រាលជ្រៅ និងសំខាន់ខ្លាំង ណាស់ ។ បន្ទាប់ពីបានដើរទស្សនកិច្ចនៅ មជ្ឈមណ្ឌល មនុស្សធម៌ វិសាលដ្ឋានសុខុមាលភាព និងការបើកសម្ពោធព្រះវិហារ បរិសុទ្ធមកឥឡូវនេះ ខ្ញុំមានអំណរគុណយ៉ាងក្រៃលែងចំពោះហេតុផលដែលអ្នករាល់គ្នាធ្វើនូវអ្វីដែលអ្នកត្រូវធ្វើនោះ" ។

នៅរាល់កិច្ចការកាន់កាប់ត្រួតត្រារបស់យើង គឺយើងត្រូវធ្វើតាមព្រះយេស៊ូវគ្រីស្ទ ។ យើងព្យាយាមធ្វើនូវអ្វីដែលទ្រង់ស្នើសុំឱ្យយើងធ្វើទាំងតាមរយៈការបង្រៀន និងគំរូរបស់ទ្រង់ ។ យើងសូមថ្លែងអំណរគុណដោយអស់ពីចិត្តរបស់យើងទៅកាន់សមាជិកសាសនាចក្រ សំរាប់ការបរិច្ចាគដ៏សប្បុរស និងការបំរើដូចជាព្រះគ្រីស្ទរបស់ពួកគេ ។

ដោយលើកឡើងពីការតមអាហារ និងផ្តល់ចំណីដល់អ្នកស្រេកឃ្លាន និងស្លៀកពាក់ឱ្យមនុស្សអាក្រាត នោះអេសាយបានសន្យានៅក្នុងពាក្យពេចន៍ដ៏ក្ដុកក្ដួលថា "គ្រានោះ បើឯងអំពាវនាវ ព្រះយេហូវ៉ានឹងតបឆ្លើយ" ។ 21 អេសាយបានបន្តទៀតថា "ហើយបើឯងផ្ដល់សេចក្ដីសប្បុរសដល់មនុស្សស្រេកឃ្លានទាំងចំអែតចិត្តនៃអ្នកដែលមានទុក្ខវេទនា... ព្រះយេហូវ៉ាទ្រង់នឹងនាំផ្លូវឯងជានិច្ច... ហើយដូចជាក្បាលទឹកដែលមិនខានហូរឡើយ... [ហើយ] ឯងនឹងសង់ឡើងលើ ជើងជញ្ជាំងដែលមាន នៅតាំងពីច្រើនដំណតមកហើយ..." ។ 22

ខ្ញុំមានសេចក្ដីសង្ឃឹមថា សូមឱ្យយើងម្នាក់ៗពិនិត្យឡើងវិញនូវការកាន់កាប់ត្រួតត្រាផ្ទាល់ខ្លួន និងគ្រួសារដែលយើងត្រូវមានទំនួលខុសត្រូវនោះ ។ ខ្ញុំសូមអធិស្ឋានថា យើងនឹងធ្វើបែបនេះ ដោយដឹងថាពិតជានឹងទទួលខុសត្រូវចំពោះព្រះ ហើយថានៅក្នុងជីវិតនេះ យើងនឹងប្រកាន់ខ្ជាប់នឹងការគោរពដោយគ្មានការបង្ខិតបង្ខំ ។

ខ្ញុំមានអំណរគុណចំពោះដំបូន្មានរបស់ព្យាការីជាទីស្រឡាញ់ ស្មោះត្រង់ ដែលបំរើ និងជួយសង្គ្រោះអ្នកទាំងឡាយ ដែលមានតំរូវការ ។ នៅពេលយើងធ្វើតាមពាក្យទូន្មានលោក ខ្ញុំដឹងថា យើងនឹងមានគុណសម្បត្តិគ្រប់គ្រាន់ចំពោះ ការសន្យារបស់ព្រះអម្ចាស់ដែលចែងថា "ហើយអស់អ្នកណាដែលឃើញថា ជាអ្នកកាន់កាប់ត្រួតត្រាដោយស្មោះត្រង់ យុត្តិធម៌ និងឈ្លាសវៃ នោះ នឹងត្រូវបានចូលទៅក្នុងសេចក្ដីអំណរនៃព្រះអម្ចាស់របស់ខ្លួន ហើយនឹងបានគ្រងជីវិតដ៏នៅអស់កល្បជានិច្ចទុកជាមរតក" ។ 23
ខ្ញុំសូមថ្លែងទីបន្ទាល់របស់ខ្ញុំពីសេចក្ដីពិតដ៏ពិសិដ្ឋនេះ ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. Rabbi Haskel Lookstein ប្រធានក្រុមប្រឹក្សាអ្នកប្រាជ្ញនៅណៅយ៉ូក ប្រធាន Synagogue Council of America និងប្រធាន National Rabbinic Cabinet នៃ UJA ។

2. "The Talmud is the repository of thousands of years of Jewish wisdom, and the oral law... finds expression therein" (Adin Steinsaltz, *The Essential Talmud* [2006], 4) ។

3. John Fletcher Moulton បានដកស្រង់ចេញពី Clayton M. Christensen, "The Importance of Asking the Right Questions" សុន្ទរកថា ធ្វើឡើងនៅការចាប់ផ្ដើមសាកលវិទ្យាល័យ Southern New Hampshire University ថ្ងៃទី 16 ខែ ឧសភា ឆ្នាំ 2009 សូមមើល Moulton, John Fletcher, English jurist "Three Domains of Human Action" ផងដែរ ។ សូមមើល ចោទិ. 6:4--7 ផងដែរ ។

4. គ. និង ស. 101:78 ។

5. សូមមើលផងដែរ គ. និង ស. 20:71 ។ អស់អ្នកដែលមានទំនួលខុសត្រូវ គួរតែប្រែចិត្ត និងទទួលបុណ្យជ្រមុជទឹក (សូមមើល គ. និង ស. 18:42) ។ បុគ្គលណាដែលបានទទួលមរណភាពពីមុនអាយុដែលមានទំនួលខុសត្រូវគឺត្រូវបានសង្គ្រោះនៅក្នុងនគរសេឡេស្ទាល (សូមមើល គ. និង ស. 137:10 សូមមើលផងដែរ គ. និង ស. 29:46--47, 50) ។

6. Spencer W. Kimball "Welfare Services: The Gospel in Action" *Ensign* ខែ វិច្ឆិកា ឆ្នាំ 1977 ទំព័រ 78 ។

7. See Gregory Katz "U.K. Health Booklet's Message: Teen Sex Can Be Fun" *Deseret News* ថ្ងៃទី ខែ កក្កដា ឆ្នាំ 2009 ទំព័រ A9 ។

8. គ. និង ស. 1:31 ។

9. "សុន្ទរកថា" នៅក្នុង Collected Poems of John Holmes, http://hdl.handle.net/10427/14894 ។

10. សូមមើល គ. និង ស. 20:37 នីហ្វៃទី 2 2:7 អាលម៉ា 39 នីហ្វៃទី 3 9:20 ។ ប្រធាន អ៊ែសរ៉ា ថាហ្វ បែនសឹន បានឱ្យនិយមន័យលើពាក្យចិត្តសង្រេង និងវិញ្ញាណទន់ទាប បែបនេះថា : "សេចក្ដីព្រួយដែលគាត់ព្រះហឫទ័យដល់ព្រះ... គឺជាការយល់ដឹងដ៏ជ្រាលជ្រៅថា ទង្វើររបស់យើងបានធ្វើឱ្យព្រះវរបិតា និងព្រះរបស់យើងអាក់អន់ព្រះទ័យ ។ វាគឺជាការដឹងខ្លួនយ៉ាងច្បាស់លាស់... អំពើបាបរបស់យើងបានធ្វើឱ្យទ្រង់ [ព្រះអង្គសង្គ្រោះ] ហូរឈាមចេញពីគ្រប់រន្ធញើស ។ ការឈឺចាប់ខាងផ្លូវចិត្ត និងខាងវិញ្ញាណនេះ គឺជាអ្វីដែលព្រះគម្ពីរបានលើកឡើងថា ជាការមាន 'ចិត្តសង្រេង និងវិញ្ញាណទន់ទាប'" "A Mighty Change of Heart" នៅ Tambali ខែ មីនា ឆ្នាំ 1990 ទំព័រ 5 *Ensign* ខែ តុលា ឆ្នាំ 1989 ទំព័រ 4 ។

11. អាលម៉ា 42:29 ។

12. គ. និង ស. 58:42 ។

13. សូមមើល Robert D. Hales "Understandings of the Heart" នៅក្នុង *Brigham Young University 1987--88 Devotional and Fireside Speeches* (1988), 129 សូមមើលផងដែរ នីហ្វៃទី 2 9:41 ។

14. សូមមើល Joseph Fielding Smith, *Take Heed to Yourselves!* ចងក្រងដោយ Joseph Fielding Smith Jr. (1971), 221 ។

15. សូមមើល ម៉ាកុស 7:20--23 ។

16. "ក្រុមគ្រួសារ: ការប្រកាសដល់ពិភពលោក" *Liahona* ខែ តុលា ឆ្នាំ 2004, 49 សូមមើលផងដែរ Russell M. Nelson "Set in Order Thy House" *Liahona* ខែ មករា ឆ្នាំ 2002, 80--83 *Ensign* ខែ វិច្ឆិកា ឆ្នាំ 2001 ទំព័រ 69-71 ។

17. សូមមើល គ. និង ស. 104:18 ។

18. Anne Morrow Lindbergh, quoted in Neal A. Maxwell ""Wisdom and Order" *Liahona* ខែ ធ្នូ ឆ្នាំ 2001, 20 ។

19. ម៉ូសាយ 4:27 ។

20. ជាងដប់ឆ្នាំកន្លងមកហើយ សាសនាចក្របានផ្តល់ជាអំណោយ និងជំនួយផ្នែកសម្ភារជាជំនួយមនុស្សធម៌ និងពេលវេលានៃការបំរើរបស់បុរស និងស្ត្រីដែលរាប់មិនអស់សរុបជាង $ 900 ។ ឧទាហរណ៍ ដោយត្រៀមបំរុងចំពោះព្យុះ Hurricane Katrina នោះពួកបុរសបានធ្វើការបំរើយ៉ាងខ្លាំងក្លា និងមានការលះបង់ខ្ពស់ជាង 330,000 ម៉ោង (របាយការណ៍មកពីពួក 70 នាក់ John Anderson ដែលគ្រប់គ្រងលើកិច្ចការជួយសង្គ្រោះនោះ) ។

21. អេសាយ 58:9 ។

22. អេសាយ 58:10--12 ។

23. គ. និង ស. 51:19 សូមមើលផងដែរ ម៉ាថាយ 25:34--46 ។